00411310

ព្រះរាជាណាចក្រកម្ពុជា 7

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / DEC / 2009
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/០៩-១០-២០០៩-អវតក/អបជ(០១)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 09 / DEC / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

---

**សាធារណៈ:**

# សាលដីកាលើពាក្យបណ្តឹងដិតចិត្តរបស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel LEMONDE

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉ែត ចរិយា
William SMITH
សេង ប៊ុនឃាង
Anees AHMED

**សហចៅក្រមស៊ើបអង្កេត**
Marcel LEMONDE

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីការពារជនត្រូវចោទ**
អាង ឧត្តម
Michael G. KARNAVAS

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៨១៤ ទូរសារ (៨៥៥) ២៣ ២១៩ ៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, Cambodia, PO Box 71, Tel: (855) 23 219 814 Fax: (855) 23 219 841 Web: www.eccc.gov.kh

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**") បានទទួល "ពាក្យបណ្តឹងមិនគិតចិត្តចំពោះសហចៅក្រមស៊ើបអង្កេត Marcel LEMONDE និងសំណើសុំបើកសវនាការសាធារណៈ" ("ពាក្យបណ្តឹង") ដែលបានដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទ អៀង សារី ("ជនត្រូវចោទ")។

## I- **សេចក្តីផ្តើម**

១. សហមេធាវីការពារក្តីជនត្រូវចោទបានដាក់ពាក្យបណ្តឹង កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២00៩[១]។

២. នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២00៩ ចៅក្រម Lemonde បានដាក់សំណើសុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងពាក្យបណ្តឹង[២]។ សហមេធាវីការពារក្តីជនត្រូវចោទ មិនបានដាក់ចម្លើយតបទៅនឹងសំណើសុំពន្យារពេលឆ្លើយតបនេះទេ។

៣. នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២00៩ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយតបបឋម" ទៅនឹងពាក្យបណ្តឹង[៣] ដោយស្នើឲ្យអង្គបុរេជំនុំជម្រះ ផ្តល់ពេលវេលាដល់ខ្លួនយ៉ាងតិចណាស់រយៈពេល១៥ថ្ងៃ ដើម្បីធ្វើការឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សរ ដែលដាក់ដោយចៅក្រម Lemonde នៅក្នុងការឆ្លើយតបទៅនឹងពាក្យបណ្តឹង។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២00៩ អង្គ

---

[១] ពាក្យបណ្តឹងរបស់ជនត្រូវចោទ អៀង សារី សុំមិនគិតចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde និង សំណើសុំបើកសវនាការសាធារណៈ" ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២00៩ សំណុំរឿង 00២/៩-១0-២00៩-អវតក/អបជ(0១) ឯកសារលេខ ១។

[២] "សំណើសុំពន្យារពេលឆ្លើយតបទៅនឹងពាក្យបណ្តឹងមិនគិតចិត្ត" 00២/៩-១0-២00៩-អវតក/អបជ(0១) ឯកសារលេខ ២។

[៣] "ចម្លើយតបបឋមរួមរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យបណ្តឹងមិនគិតចិត្តរបស់ជនត្រូវចោទ អៀង សារី និង ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ" សំណុំរឿង 00២/៩-១0-២00៩-អវតក/អបជ(0១) ឯកសារលេខ ៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

បុរេជំនុំជម្រះបានសម្រេចថា ផ្នែកខ្លះនៃ "ចម្លើយតបបឋម" របស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបាន ហេតុដូច្នេះហើយបានសម្រេចបដិសេធសំណើសុំរបស់សហព្រះរាជអាជ្ញា[៤]។

៤. ចៅក្រម Lemonde បានដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន អនុលោមតាមវិធាន ៣៤(៧)[៥] កាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ យោងតាមមាត្រា៨ នៃសេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/ វិសោធនកម្មលើកទី៤។

## II. សេចក្ដីសង្ខេបសារណានានា

៥. ពាក្យបណ្ដឹងបានស្នើសុំផិតចិត្តចំពោះចៅក្រម Lemonde ផ្អែកតាមពាក្យសម្ដីដែលគាត់បាននិយាយនៅក្នុងកិច្ចប្រជុំមួយជាមួយនឹងបុគ្គលិកមួយចំនួន នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") កាលពីខែសីហា ឆ្នាំ២០០៩។ គេបានចោទប្រកាន់ថា ចៅក្រម Lemonde បាននិយាយថា "ខ្ញុំចង់ឲ្យពួកយើងស្វែងរកភស្តុតាងដាក់បន្ទុក ឲ្យបានច្រើនជាងភស្តុតាងដោះបន្ទុក"។ លោក Wayne Bastin អតីតប្រធានអង្គភាពផ្នែកស៊ើបការណ៍ និងផ្នែកវិភាគនៃ ក.ស.ច.ស បានផ្ដល់សេចក្ដីថ្លែងការណ៍ចំនួនបីទំព័រដែលបានកំណត់អំពីរឿងរ៉ាវនៃកិច្ចប្រជុំនេះ ដល់សហមេធាវីការពារក្ដីជនត្រូវចោទ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ ២០០៩។ សេចក្ដីថ្លែងការណ៍ដែលបានដាក់ភ្ជាប់មកជាមួយពាក្យបណ្ដឹង មានសេចក្ដីប្រកាសមួយ ដែលទំនងជាបានចុះហត្ថលេខាដោយលោក Bastin និងត្រូវបានគេឃើញនៅឯប៉ុស្តិ៍នគរបាលអូស្ត្រាលីមានសេចក្ដីថា "តាមរយៈនេះ ខ្ញុំទទួលស្គាល់ថា សេចក្ដីថ្លែងទាំងនេះគឺជាការពិត និងត្រឹមត្រូវ ហើយខ្ញុំជឿជាក់ថា អ្នកដែលបានបង្កើតនូវសេចក្ដីប្រកាសដែលខុសជាផលវិបាកនឹងត្រូវទទួលខុសត្រូវចំពោះការដាក់ទោសលើការនិយាយភូតភរតុលាការ"។

---

[៤] "សេចក្ដីសម្រេចលើចម្លើយតបបឋមរួមរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យបណ្ដឹងផិតចិត្តរបស់ជនត្រូវចោទ អៀង សារី និង ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ" សំណុំរឿង ០០២/៩-១០-២០០៩-អវតក/អបជ(០១) ឯកសារលេខ ៦។

[៥] "ចម្លើយរួបរួមគ្នាធ្វើដោយសហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងពាក្យបណ្ដឹងផិតចិត្តដែលបានដាក់ក្នុងនាម ជនត្រូវចោទ អៀង សារី និង ខៀវ សំផន" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ៤។

៦. សហមេធាវីការពារក្ដីជនត្រូវចោទលើកឡើងថា ពាក្យសម្ដីរបស់ចៅក្រម Lemonde ដែលបានដកស្រង់នៅក្នុងសេចក្ដីថ្លែងការណ៍របស់លោក Bastin បង្ហាញឲ្យឃើញនូវភាពលម្អៀងជាក់ស្ដែងរបស់ចៅក្រម Lemonde និងភាពទំនងថា មានភាពលម្អៀងផងដែរ។ សហមេធាវីការពារក្ដីជនត្រូវចោទ ស្នើសុំឲ្យមានការបើកសវនាការសាធារណៈលើពាក្យបណ្ដឹង "ដោយមានការចូលរួមពីអ្នក ដែលបានបានចូលរួមក្នុងកិច្ចប្រជុំជាលក្ខណៈឯកជនជាមួយចៅក្រម Marcel LEMONDE ដើម្បីផ្ដល់សក្ខីកម្ម ដោយមានការធ្វើសច្ចាប្រណិធាន"[៦]។

៧. នៅក្នុងចម្លើយតបរបស់ខ្លួន ចៅក្រម Lemonde លើកឡើងថា គាត់មិនបានចងចាំថា គាត់បាននិយាយពាក្យសម្ដីដែលគាត់ត្រូវទទួលខុសត្រូវបញ្ហានោះទេ និងថា ប្រសិនបើគាត់បាននិយាយពាក្យសម្ដីទាំងនោះមែន វានឹងគ្រាន់តែជា "ការនិយាយលេងសើចតែប៉ុណ្ណោះ នៅពេលដែលអ្នកទាំងអស់គ្នា ដែលមានវត្តមាននៅទីនោះក៏បានស្ដាប់ឮក្នុងលក្ខណៈដូច្នោះដែរ"[៧]។ ចៅក្រម Lemonde សន្និដ្ឋានថា ពាក្យបណ្ដឹងមិនបានបង្ហាញភាពលម្អៀងជាក់ស្ដែង ឬភាពទំនងថាមានភាពលម្អៀង ហើយដូច្នេះហើយ ពាក្យបណ្ដឹងគួរតែត្រូវបានបដិសេធចោល[៨]។

៨. ចៅក្រម Lemonde បានបន្ថែមលើចម្លើយតបរបស់គាត់នូវ "ចម្លើយសាក្សី" ដែលបានចុះហត្ថលេខារួច ដែលបានលើកឡើងអំពីការចងចាំអំពីកិច្ចប្រជុំខែសីហា ឆ្នាំ២០០៩ ផ្ទាល់ខ្លួនរបស់គាត់[៩]។

---

[៦] ពាក្យបណ្ដឹង បន់ស្រន់សុំឲ្យដោះលែង កថាខណ្ឌទី ៣០ff។

[៧] "ចម្លើយរួបរួមគ្នាធ្វើដោយសហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងពាក្យបណ្ដឹងឌិតចិត្តដែលបានដាក់ក្នុងនាម ជនត្រូវចោទ អៀង សារី និង ខៀវ សំផន" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ៤ កថាខណ្ឌទី៨ ។

[៨] "ចម្លើយរួបរួមគ្នាធ្វើដោយសហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងពាក្យបណ្ដឹងឌិតចិត្តដែលបានដាក់ក្នុងនាម ជនត្រូវចោទ អៀង សារី និង ខៀវ សំផន" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ៤ កថាខណ្ឌទី៩។

[៩] "ចម្លើយរួបរួមគ្នាធ្វើដោយសហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងពាក្យ[illegible] ក្នុងនាម ជនត្រូវចោទ អៀង សារី និង ខៀវ សំផន-ឧបសម្ព័ន្ធ ក" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០[illegible]
**សាលដីកាលើពាក្យបណ្ដឹងឌិតចិត្តរបស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអ[illegible] ចៅក្រម Marcel LEMONDE**

00411314



## III. ភាពអាចទទួលយកបាននៃពាក្យបណ្តឹង

៩. យុត្តាធិការនៃអង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងពាក្យបណ្តឹងត្រូវបានកំណត់ដោយវិធាន៣៤(២) នៃវិធានផ្ទៃក្នុង ដែលចែងថា:

> “ភាគីអាចធ្វើបណ្តឹងជិតចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាង ពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលម្អៀង”។

១០. វិធាន៣៤(៥) ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា “ពាក្យបណ្តឹងជិតចិត្ត ចំពោះសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះ”។ បទបញ្ញត្តិទាំងអស់នេះមានន័យថា អង្គបុរេជំនុំជម្រះមានយុត្តាធិការ ក្នុងការពិចារណាលើពាក្យបណ្តឹង។

១១. កាតព្វកិច្ចនានារបស់ភាគី ដែលដាក់ពាក្យបណ្តឹងជិតចិត្តចំពោះចៅក្រម ត្រូវបានកំណត់នៅក្នុងវិធាន៣៤(៣) នៃវិធានផ្ទៃក្នុង:

> “ភាគីដែលធ្វើបណ្តឹងជិតចិត្ត ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ។ ពាក្យបណ្តឹងត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ”។

១២. សហមេធាវីការពារក្តីជនត្រូវចោទលើកឡើងថា ពួកគាត់បានយកចិត្តទុកដាក់ លើព័ត៌មានដែលមាននៅក្នុងសេចក្តីថ្លែងការណ៍របស់លោក Bastin កាលពីដើមខែតុលា ឆ្នាំ២០០៩[១០]។ សេចក្តីថ្លែងការណ៍ ដែលមានហត្ថលេខាលោក Bastin ដែលបានដាក់ជាឧបសម្ព័ន្ធជាមួយពាក្យបណ្តឹងបានចុះកាលបរិច្ឆេទថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩។ អង្គបុរេជំនុំជម្រះយល់ឃើញ

---

[១០] ពាក្យបណ្តឹង កថាខណ្ឌទី ៤។

ថា ពាក្យបណ្ដឹងដែលបានដាក់កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ មានកំណត់ពេលវេលានៅក្នុងបទបញ្ញត្តិនៃវិធាន៣៤(៣) នៃវិធានផ្ទៃក្នុង។

១៣. វិធាន៣៤(៧) នៃវិធានផ្ទៃក្នុង កំណត់អំពីនីតិវិធីដើម្បីអនុវត្តតាម អាស្រ័យតាមការទទួលបានពាក្យបណ្ដឹងជំទាស់ចំពោះចៅក្រម:

> “ចៅក្រមដែលត្រូវបានគេប្ដឹងជំទាស់ប្រឆាំងនឹងខ្លួន មានសិទ្ធិដាក់សារណាទៅអង្គជំនុំជម្រះតាមរយៈប្រធានរបស់ខ្លួន ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ គិតចាប់ពីថ្ងៃដែលគាត់បានទទួលពាក្យបណ្ដឹង។ ពាក្យបណ្ដឹងជំទាស់ ព្រមទាំងសារណារបស់ចៅក្រមដែលត្រូវគេប្ដឹងជំទាស់ ត្រូវយកមកពិចារណាដោយអង្គជំនុំជម្រះ ដែលត្រូវបោះឆ្នោត និងធ្វើសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរលើបញ្ហានេះ ដោយពុំមានវត្តមានរបស់ចៅក្រមដែលត្រូវបានគេប្ដឹង និងដើមបណ្ដឹង”។

១៤. នៅក្នុងវិធាន៣៤(៧) នៃវិធានផ្ទៃក្នុង ពុំមានបទបញ្ញត្តិណាមួយត្រូវបានចែងអំពីការបើកសវនាការសាធារណៈ ឬអំពីការឆ្លើយតបជាលាយលក្ខណ៍អក្សរនោះទេ[១១]។ រាល់ភស្តុតាងដែលគាំទ្រ ដែលសំអាងដោយអ្នកដាក់ពាក្យបណ្ដឹងទាំងអស់ ត្រូវដាក់ជាមួយនឹងពាក្យបណ្ដឹងជំទាស់ ដូចដែលបានកំណត់លក្ខខណ្ឌដោយវិធាន៣៤(៣) នៃវិធានផ្ទៃក្នុង។

១៥. អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីលើកមុនថា នៅក្នុងបណ្ដឹងជំទាស់ចំពោះចៅក្រម “ការស្វែងរកភស្តុតាង គឺជាបន្ទុករបស់អ្នកដាក់បណ្ដឹងទាំងស្រុង”[១២]។ ភាពអនាគតិរបស់ចៅក្រមត្រូវបានសន្មតទុកជាមុន លើកលែងតែមានការបង្ហាញភស្តុតាងផ្ទុយពីនេះ។ ភស្តុតាងដើម្បីដក

---

[១១] សូមមើល “សេចក្ដីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំចាត់វិធានការសមស្រប ពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍របស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ Katinka Lahuis និង Rowan Downing” សំណុំរឿង ០០២/២០-១០-២០០៩-អវតក/អបជ(០៣) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌទី២។

[១២] “សេចក្ដីសម្រេចលើចម្លើយតបបឋមរួមរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យបណ្ដឹងជំទាស់របស់ជនត្រូវចោទ អៀង សារី និង ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ” សំណុំរឿង ០០២/០៩-១០-២០០៩-អវតក/អបជ(០១) ឯកសារលេខ ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ចេញនូវការសន្មតទុកជាមុននេះ ត្រូវតែបានលើកហេតុផលនៅពេលដាក់ពាក្យបណ្ដឹង។ ដូច្នេះ ពាក្យបណ្ដឹងមិនអាចទទួលយកបានទេ បើវាគ្រាន់តែជាពាក្យបណ្ដឹង ស្នើសុំឱ្យបើកសវនាការសាធារណៈតែប៉ុណ្ណោះនោះ។

## IV- **ការពិចារណាលើពាក្យបណ្ដឹង**

១៦. នៅក្នុងសេចក្ដីសម្រេចកាលពីលើកមុនរបស់ខ្លួន ពាក់ព័ន្ធនឹងពាក្យបណ្ដឹងជំទាស់ចំពោះចៅក្រម ន័យ ថុល[១៣] អង្គបុរេជំនុំជម្រះបានរៀបចំច្បាប់ ដែលអនុវត្តនៅក្នុងករណីនៃការជំទាស់។ លក្ខណៈវិនិច្ឆ័យអំពីភាពលម្អៀងដើម្បីយកទៅអនុវត្ត គឺបានចែងនៅក្នុងវិធាន៣៤(២) នៃវិធានផ្ទៃក្នុង ដែលលើកឡើងទាំងភាពលម្អៀងជាក់ស្ដែង ទាំងភាពលម្អៀងដែលត្រូវបានគេយល់ឃើញ[១៤]។

១៧. កថាខណ្ឌទី១៥ ដល់២១ នៃមូលហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្ដីសម្រេចលើករណីចៅក្រម ន័យ ថុល (កំណត់សម្គាល់ជើងទំព័រត្រូវបានលុបចោល) មានដូចខាងក្រោម:

> *១៥. "អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា "ចំណុចចាប់ផ្ដើមនៃការសម្រេចលើការជំទាស់អំពី [ភាពលម្អៀង] គឺថា "មានការសន្មតទុកជាមុនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម"។ "ការសន្មតនេះ កើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងគាត់ [...] និងដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគីដែលធ្វើបណ្ដឹងជំទាស់ក្នុងការដកចេញនូវការសន្មតទុកជាមុននេះ"។*
>
> *១៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការសន្មតអំពីភាពអនាគតិនេះ គឺអនុវត្តចំពោះចៅក្រមទាំងអស់នៃ អ.វ.ត.ក។ មាត្រា ៣.៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ*

---

[១៣] "សេចក្ដីសម្រេចលើបណ្ដឹងបន្ទាន់របស់សហមេធាវីការពារក្ដីសុំជំទាស់ចំពោះចៅក្រម ន័យ ថុល ដែលបានផ្អាកបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងរឿងក្ដីរបស់ជនត្រូវចោទ នួន ជា" សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អវតក/កសចស (អបជ ០១) ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29។ សូមមើលផងដែរ ពាក្យបណ្ដឹង កថាខណ្ឌទី១៤។

[១៤] សូមមើល កថាខណ្ឌទី១០ ខាងលើ។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ចែងថា:

> ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិតមានគុណសម្បត្តិដែលតម្រូវ សម្រាប់តែងតាំងឲ្យបម្រើការងារក្នុងការិយាល័យតុលាការនៅក្នុងប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យ ក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។
>
> តាមមាត្រា ៧.២ នៃកិច្ចព្រមព្រៀង បទបញ្ញត្តិនេះត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ។

១៧. មាត្រា១០ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា "ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែងតាំងចេញពីក្នុងចំណោម ចៅក្រមដែលកំពុងបំពេញ ការងារបច្ចុប្បន្ន ឬទទួលការតែងតាំងបន្ថែមយោងតាមនីតិវិធី ដែលមានស្រាប់សម្រាប់ការតែងតាំងនេះ ចៅក្រមទាំងអស់ ត្រូវមានចរិតលក្ខណៈសីលធម៌ខ្ពស់ ស្មារតីអនាគតិ ភាពសុច្ចរិត និងជាពិសេសមានបទពិសោធន៍ក្នុងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិរួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង។ ចៅក្រមទាំងអស់ត្រូវស្ថិតនៅឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវទទួលយក ឬស្វែងរកការណែនាំណាមួយពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ"។

១៨. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦ ចៅក្រមនៃអង្គបុរេជំនុំជម្រះរបស់អ.វ.ត.ក រួមទាំងចៅក្រម ន័យ ថុល ផងដែរ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងបានធ្វើសច្ចាប្រណិធានជាផ្លូវការក្នុងពិធីផ្លូវការមួយ។

១៩. ក្នុងបញ្ហានេះ អ្នកប្តឹងដិតចិត្តត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ដល់អង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានប្តឹងចោទប្រកាន់នោះ អាចមានភាពលម្អៀងពិតប្រាកដមែន។ នៅមានចំណុចជាមូលដ្ឋានជាច្រើនដែលត្រូវបំពេញ ដើម្បីជំទាស់ទៅនឹងការសន្មតជាមុននៃភាពអនាគតិ។

២០. *យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ គឺមានលក្ខណៈដូចគ្នាក្នុងការធ្វើការវាយតម្លៃអំពីភាពលម្អៀងដែលបានអនុវត្តក្នុងពេលនេះ។ សាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានយល់ឃើញក្នុងករណីរបស់ហ្វូរ៉ាន់ហ្ស៊ីហ្សា (Furundzija) ថា:*

> *ចៅក្រមមួយរូបត្រូវបានចាត់ទុកថា មានភាពលម្អៀង ប្រសិនបើត្រូវបានរកឃើញថា មានសកម្មភាពលម្អៀងពិតប្រាកដមែន។*
>
> *មានការលម្អៀងតាមរយៈការមើលឃើញពីខាងក្រៅ ប្រសិនបើ:*
>
> *ចៅក្រមមួយរូបជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធិ ដែលបានមកពីរឿងក្តីនោះ ឬប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រមនឹងនាំឱ្យមានការគាំទ្រដល់រឿងក្តីមួយដែលរូបគាត់មានការពាក់ព័ន្ធជាមួយភាគីណាមួយនៃរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះ ត្រូវដកខ្លួនចេញពីរឿងក្តីនោះ ដោយស្វ័យប្រវត្តិ ឬ*
>
> *ក្នុងកាលៈទេសៈ ដែលអាចនាំឱ្យមានការកត់សម្គាល់មួយដ៏សមហេតុផល និងមានព័ត៌មានត្រឹមត្រូវចំពោះការយល់ដឹងអំពីភាពលម្អៀងដោយសមហេតុផល។*
>
> *យុត្តិសាស្ត្រនេះ ត្រូវបានអនុវត្តជាទូទៅដោយតុលាការអន្តរជាតិ។*

២១. *អ្នកសង្កេតការណ៍ដ៏សមហេតុផលក្នុងការវាយតម្លៃអំពីភាពលម្អៀងនេះ គឺត្រូវតែជា "បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់យល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពមិនលម្អៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិ គឺជាករណីយកិច្ចមួយក្នុងចំណោមករណីយកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រលើកតម្កើង"។*

១៨. *ក្រមសីលធម៌តុលាការ*របស់អង្គជំនុំជម្រះវិសាមញ្ញ បានចែងអំពីគោលការណ៍ណែនាំបន្ថែមទៀតនៅក្នុងផ្នែកនេះ។ មាត្រា២.១ ចែងថា "ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង និងត្រូវ

ធានាពីការបង្ហាញពីភាពមិនលម្អៀងនោះនៅក្នុងការបំពេញតួនាទីរបស់ខ្លួន"[១៥]។ មាត្រា៧.១ ចែងថា "ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណា ដែលសមស្រប ជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនង ជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ"។

១៩. មាត្រា២.២ នៃគោលការណ៍វិជ្ជាជីវៈតុលាការ Bangalore (Bangalore Principles of Judicial Conduct) លើកឡើងថា ចៅក្រម "ត្រូវធានាថា ការប្រព្រឹត្តិរបស់ខ្លួន ទាំងក្នុង និង ក្រៅតុលាការ ថែរក្សា និងបង្កើននូវសេចក្ដីទុកចិត្តរបស់សាធារណជន វិជ្ជាជីវៈច្បាប់ និងគូរ វិវាទ ចំពោះភាពមិនលម្អៀងរបស់ចៅក្រម និងរបស់តុលាការ"[១៦]។ មតិយោបល់ចំពោះ អត្ថបទនេះ បន្តនិយាយថា "ចៅក្រមត្រូវចៀសវាង កិច្ចពិភាក្សាដេញដោល ដែលប្រើពាក្យ សម្ដី ឬការប្រព្រឹត្តិដែលអាចនាំឲ្យមានការយល់ឃើញថា មានភាពលម្អៀង" និងថា "កំណត់ សម្គាល់ដែលចៅក្រមអាចពិចារណាឃើញថាជា "ការលេងសើចដែលមិនបង្កទុក្ខទោសអ្វីទេ" នោះ អាចកាត់បន្ថយនូវភាពមិនលម្អៀងរបស់ចៅក្រម ដែលត្រូវបានគេយល់ឃើញ"[១៧]។

២០. រាល់ភស្តុតាងទាំងអស់ដែលសំអាងដោយអ្នកដាក់ពាក្យបណ្ដឹង ត្រូវធ្វើការផ្ដល់ឲ្យតាមការដាក់ ពាក្យបណ្ដឹងផិតចិត្ត។ ភស្តុតាងដែលផ្ដល់ដោយសហមេធាវីការពារក្ដីជនជាប់ចោទ

---

[១៥] ក្រមសីលធម៌តុលាការ ដែលបានអនុម័តនៅកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃ ទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានធ្វើវិសោធនកម្មនៅកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨។

[១៦] បានអនុម័តដោយក្រុមពង្រឹងសុចរិតភាពតុលាការ ដែលបានកែប្រែនៅកិច្ចប្រជុំតុមូលរបស់ Chief Justices ដែលបាន ធ្វើឡើងនៅវិមានសន្តិភាព ទីក្រុងឡាអេ នាថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០០២។ ចំពោះការអនុវត្តគោលការណ៍ the Bangalore Principles នៅតុលាការពិសេសសេរ៉ាឡេអូន សូមមើល "សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំបើកសវនាការក្នុងពេល ដំណាលគ្នាលើភស្តុតាងរួមគ្នារបស់រឿងក្ដី SCSL-2004-15-PT និង SCSL-2004-16-PT" រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Sesay សំណុំរឿងលេខ SCSL-04-15-PT អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៤ កឋាខណ្ឌទី៣៨។

[១៧] មតិយោបល់លើគោលការណ៍ the Bangalore Principles of Judicial Conduct [illegible] ខែមីនា ឆ្នាំ២០០៧ កឋាខណ្ឌទី៦៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ដើម្បីគាំទ្រដល់ពាក្យបណ្តឹង មាន "ចម្លើយ" ចំនួនបីទំព័រដែលបានចុះហត្ថលេខាដោយលោក Bastin និងបានឃើញច្បាស់ដោយមនុស្សម្នាក់នៅប៉ុស្តិ៍នគរបាលអូស្ត្រាលី។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីនិយាយអំពីសេចក្តីថ្លែងការណ៍របស់លោក Bastin ដែលជាក់ស្តែងមិនត្រឹមត្រូវនោះទេ[១៨]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថែមទៀតថា ពុំមានការគូសបញ្ជាក់អំពីអត្តសញ្ញាណរបស់លោក Bastin ដោយសាក្សីណាមួយដើម្បីយកមកបង្ហាញនៅពេលដែលចម្លើយនោះ ត្រូវបានផ្តល់ឱ្យនោះទេ។ កាលៈទេសៈទាំងអស់នេះ ជះឥទ្ធិពលដល់តម្លៃនៃភស្តុតាងដែលបានបង្ហាញ។

២១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្នុងចំណោមបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបាននិយាយថា បានចូលរួមនៅក្នុងកិច្ចប្រជុំកាលពីខែសីហា ឆ្នាំ២០០៩ នោះ មានតែលោក Bastin តែម្នាក់ប៉ុណ្ណោះ ដែលបានផ្តល់នូវរឿងរ៉ាវដែលគាត់ចងចាំ។ នៅក្នុងសេចក្តីថ្លែងរបស់គាត់ លោក Bastin និយាយថា នៅក្នុងពេលប្រជុំ គាត់បាន "ធ្វើកត់ត្រាជាចំណុចសម្គាល់ខ្លីៗ" ដែលគាត់នៅរក្សាវានៅឡើយ។ កំណត់សម្គាល់ដែលកើតមាននៅពេលជំណាលគ្នាទាំងអស់នេះ មិនទាន់បង្កើតឡើងនៅឡើយទេ។ ពុំមានការពន្យល់លើបញ្ហានេះ ឬលើបញ្ហាដែលគ្មានចម្លើយ ដែលផ្តល់ឱ្យពីសាក្សីផ្សេងទៀតដែលអាចផ្តល់នូវការបញ្ជាក់បន្ថែមនោះទេ។ លើសពីនេះទៀត ចម្លើយរបស់លោក Lemonde ពុំមានផ្តល់នូវបរិបទនៃការសន្ទនាដែលក្នុងនោះនិយាយថា ពាក្យសម្តីរបស់ចៅក្រម Lemonde ត្រូវបាននិយាយចេញមកនោះទេ។

២២. បរិបទដែលគេបាននិយាយថា ចៅក្រម Lemonde បាននិយាយពាក្យសម្តីសំដៅទៅលើខ្លួនគាត់ នៅក្នុងកិច្ចប្រជុំឯកជនមួយដែលបានធ្វើឡើងជាមួយនឹងបុគ្គលិកនៃ ក.ស.ច.ស បានធ្វើឱ្យពាក្យសម្តីទាំងនោះបង្ហាញពីភាពលម្អៀង ឬភាពទំនងថាមានមានភាពលម្អៀង តិចជាងពាក្យសម្តីដដែល ដែលត្រូវបាននិយាយដោយចៅក្រមនៅទីសាធារណៈ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា នៅកិច្ចប្រជុំនេះ ចៅក្រម Lemonde ត្រូវគេបាននិយាយថា គាត់បាននិយាយជាភាសាអង់គ្លេស ដែលមិនមែនជាភាសាកំណើត ឬជាភាសាការងាររបស់គាត់នោះទេ ដូចដែលបានបញ្ជាក់តាមរយៈសំណើរបស់គាត់ ឱ្យមានការបក[illegible]ភាសា

---

[១៨] ពាក្យបណ្តឹងជំទាស់, កថាខណ្ឌទី៥។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

អង់គ្លេសទៅជាភាសាបារាំង និងរាល់ឯកសារទាំងអស់មកពីការិយាល័យសហចៅក្រមស៊ើបអង្កេត សុទ្ធតែបានដាក់ជាភាសាបារាំង។ ហេតុដូច្នេះ ពាក្យសម្តីដែលគេបានចោទប្រកាន់ថាគាត់និយាយមិនអាចបកស្រាយថា មានន័យពេញលេញជាភាសាអង់គ្លេសនោះទេ។

២៣. បន្ទាប់ពីបានពិចារណាលើកាលៈទេសៈទាំងអស់នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ភស្តុតាងដែលគាំទ្រពាក្យបណ្តឹងមិនមានភាពរឹងមាំនោះទេ។ ភស្តុតាងនោះកាន់តែមានភាពទន់ខ្សោយថែមទៀត ប្រសិនបើពាក្យសម្តីទាំងនោះគ្រាន់តែត្រូវបាននិយាយលេងសើចប៉ុណ្ណោះ ហើយចំណុចនេះ អ្នកទាំងអស់គ្នាដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ បានស្តាប់ឮច្បាស់លាស់ណាស់ដូចដែលបានលើកឡើងដោយចៅក្រម Lemonde ដូច្នោះដែរ។ លទ្ធភាពដែលបានស្តាប់ឮដូច្នេះក៏គួរតែរួមបញ្ចូលទាំងអ្នក ដែលបានផ្តល់ភស្តុតាងនេះផងដែរ។

២៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតប្រើរយៈពេលអស់ជាងពីរឆ្នាំមកហើយនៅក្នុងការស៊ើបអង្កេតរបស់ខ្លួនលើសំណុំរឿងលេខ០០២។ តាមរយៈការបង្គាប់ឱ្យមានការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អនុលោមតាមវិធាន៦៣(៣)(ក) ចៅក្រម Lemonde បានយល់ឃើញរួចហើយថា "មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"។ តាមពិត ជនត្រូវចោទមានសិទ្ធិទទួលបាននូវការសន្មតទុកជាមុនថា គ្មានទោស និងទទួលបាននូវការស៊ើបអង្កេតមួយដែលមិនលម្អៀង។ ចរិតលក្ខណៈនៃការស៊ើបអង្កេត គឺថាវាជាការបន្តដំណើរការទទួលនិងវាយតម្លៃភស្តុតាង ដែលកំពុងឈានដល់ការសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ឬបដិសេធលើកលែងការចោទប្រកាន់។ គេកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រកាសកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ថា សហចៅក្រមស៊ើបអង្កេតមានបំណងបញ្ចប់ការស៊ើបអង្កេតនានាត្រឹមដំណាច់ឆ្នាំ ដែលមានន័យថា ពួកគាត់បានឈានជិតដល់ពេលធ្វើសេចក្តីសន្និដ្ឋានហើយ។ តាមរយៈការបង្កើតនូវមតិយោបល់លើកិច្ចស៊ើបសួរចុងក្រោយ វាហាក់ដូចជា និងមិនអាចសង្ស័យថា សហចៅក្រមស៊ើបអង្កេតមិនទំនោរ[illegible]ៈនៃភស្តុតាងដែលត្រូវបានរកឃើញនោះទេ ពីព្រោះថា មកដល់ពេលនេះ [illegible]គំនិត

ថាត្រូវសរសេរសេចក្ដីសន្និដ្ឋានយ៉ាងណាហើយ បើផ្អែកតាមភស្តុតាងទាំងអស់ដែលប្រមូលបាន។

២៥. ការបញ្ជាក់អំពីទំនោររបស់ចៅក្រមស៊ើបអង្កេតចំពោះបុគ្គលិករបស់គាត់ ត្រូវធ្វើការបែងចែកឲ្យដាច់ពីការណែនាំ ឬសេចក្ដីបង្គាប់ជាក់លាក់ ចំពោះអ្នកស៊ើបអង្កេតរបស់តុលាការ ដើម្បីស្រាវជ្រាវរកតែភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដែលកើតចេញមកពីការស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក្យសម្ដីដែលសហមេធាវីការពារក្ដីលើកឡើងចំពោះចៅក្រម Lemonde ដែលគាត់បានិយាយទៅកាន់ខ្លួនគាត់ មិនចាត់ទុកថា ជាការណែនាំ ឬសេចក្ដីបង្គាប់នោះទេ[១៩]។

២៦. តាមរយៈហេតុផលដែលបានលើកឡើង ជនត្រូវចោទមិនបានបំពេញបន្ទុក ក្នុងការស្វែងរកភស្តុតាង ដែលជាភារកិច្ចរបស់ខ្លួននោះទេ។

## V. សេចក្ដីសន្និដ្ឋាន

អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទថា:

១. តាមរយៈមូលហេតុដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី៩ ដល់ទី១៥ ខាងលើ សំណើរបស់សហមេធាវីការពារក្ដីជនត្រូវចោទសុំបើកសវនាការសាធារណៈ មិនអាចទទួលយកបានទេ។ និង

២. ហេតុដូចនេះ ពាក្យបណ្ដឹងត្រូវបានបដិសេធចោល។

**ភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩**

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING** **ន័យ ថុល** **Katinka LAHUIS** **ហួត វុធី** **ប្រាក់ គឹមសាន**

---

[19] ពាក្យបណ្ដឹងជិតចិត្ត, កថាខណ្ឌទី២៣។ ។